**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**

**អំពើជួញដូរមនុស្ស**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ

លេខ…………………………………….

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបបួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំឆ្លងរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល០៩ខែឆ្នាំ២០២២ ជាមួយថ្នាក់ដឹកនាំ គ.រ.ប.ជ និង គ.ខ.ប.ជ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង លោកប្រធានក្រុមជំនួយកិច្ចការ ប្រធានលេខាធិការដ្ឋាន ក្រុមការងាររបាយការណ៍ និងក្រុមបច្ចេកទេស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអភិបាលរង រាជធានី-ខេត្ត ប្រធានលេខាធិការដ្ឋាន គ.រ.ប.ជ គ.ខ.ប.ជ លោកស្រីជាស្នងការរង រាជធានី ខេត្ត ទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស ក្រុមការងាររបាយការណ៍ របស់លេខាធិការដ្ឋាន គ.រ.ប.ជ និង គ.ខ.ប.ជ សរុបប្រមាណ ៧០នាក់។

- **ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំបង្កើតផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស (២០២២-២០២៣) ក្រោមអធិបតីភាព **លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំ Kampus។ សិក្ខាសាលាមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ លោកជំទាវ អភិបាលរង និងជាប្រធានលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី/ខេត្ត លោក លោកស្រីស្នងការរង ទទួលផែនរាជធានី/ខេត្ត លោក លោកស្រីជាប្រធាន

អនុប្រធានមន្ទីរ នៃក្រុមការងារទាំង៦ ជុំវិញរាជធានី/ខេត្ត មន្ត្រីរបាយការណ៍រាជធានី/ខេត្ត ក្រុមការងារ របាយការណ៍ និងបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សរុបចំនួន ១២២ រូប។

- **ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការបង្កើតផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស (២០២២-២០២៣) ក្រោមកិច្ចសហការគាំទ្រដោយអង្គការ Winrock, Asian Act និងIOM ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណងបង្កើតផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២២-២០២៣) ដោយផ្អែកលើយុទ្ធសាស្ត្រ សំខាន់ៗ ៤គឺ៖

១. ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន និងដៃគូពាក់ព័ន្ធ ទ្វេភាគី ពហុភាគី ដោយផ្អែកលើការទទួលខុសត្រូវរួម ដើម្បីដោះស្រាយបញ្ហាដែលនាំឱ្យមានការជួញដូរ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងរំលោភ បំពានលើមនុស្សគ្រប់ទម្រង់ ជាពិសេសលើស្ត្រី និងកុមារ ។

២. ពង្រឹងវិធានការបង្ការទប់ស្កាត់ អំពើជួញដូរមនុស្សគ្រប់រូបភាព ។

៣. ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះ ដោយត្រូវធ្វើការកំណត់ អត្តសញ្ញាណជនរងគ្រោះឱ្យបានជាក់លាក់ ចៀសវាងការបន្លំបោកប្រាស់ពីឧក្រិដ្ឋជនក្នុង គោលដៅបង្វែរបទល្មើស។

៤. ពង្រឹងកិច្ចសហការ ជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាតិ អន្តរជាតិ ក្នុង ការស៊ើបអង្កេត បទល្មើសជួញដូរមនុស្ស ការអនុវត្តច្បាប់ដើម្បីកាត់ទោសឧក្រិដ្ឋជន ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ។

អញ្ជើញចូលរួមជាគណៈអធិបតីមាន ឯកឧត្តម ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឯកឧត្តម ហ៊ូ វុន្នី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ ហ៊ូ សាមិត្ត រដ្ឋលេខាធិការក្រសួងកិច្ចការនារី លោកជំទាវ បណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម យឹម សារី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ឯកឧត្តម ឯកឧត្តម រិទ្ធ អារុណទិត្យា អគ្គនាយកទីស្តីការគណៈរដ្ឋមន្ត្រី លោកជំទាវ អគ្គលេខាធិការ នៃអគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង តំណាងក្រសួងស្ថាប័ននៅថ្នាក់ជាតិ ដែលមានក្រុមការងារ អន្តរក្រសួង-ស្ថាប័ន ទាំង៦ក្រុម អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូសហការ ដែលជាតំណាងអង្គការ ក្រៅរដ្ឋាភិបាល ជាតិ-អន្តរជាតិរួមមាន UNICEF, USAID, IOM, AIM, ASEAN-ACT, Winrock International, Karitas Swiss, Karitas Cambodia, WHI, IJM, UNDP, ADHOC, WMI, ERIKS, SC, ACRA Chabdai, Hope of Justice, Samaritan Purse, Ratanak International , FI, WI, ILO, LSCW, CWCC, A21, គ្រួសារថ្មី និងស្ថាប័នអង្គការសហប្រជាជាតិ។

- **ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២** លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមអង្គសិក្ខាសាលាស្តីពីរបកគំហើញ របស់ការសិក្សា ស្រាវជ្រាវលើការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌សាធារណៈ លើការប្រយុទ្ធប្រឆាំងនៃអំពើជួញដូរ ពលកម្មនៅ ប្រទេសកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តម យឹម សារី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ លោកជុម សាងម នាយកស្តីទីអង្គការ IJM ។ ការអញ្ជើញចូលរួមពី លោកជំទាវ ជាអភិបាលរងខេត្ត និង លោកស្រីជាស្នងការរង ទទួលផែនប្រឆាំងការជួញដូរមនុស្ស គ.ខ.ប.ជ ពីខេត្ត ពោធិសាត់ កំពង់ចាម បន្ទាយមានជ័យ កំពង់ធំ និង មន្ត្រីតំណាងខាងមន្ទីរការងារ របស់ខេត្តសៀមរាប ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង នៃក្រុមជំនួយកិច្ចការទាំង៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន ពីអគ្គស្នងការដ្ឋាននគរបាលជាតិ លោក លោកស្រីតំណាងពីអង្គការដៃគូរ ពាក់ព័ន្ធ ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះត្រូវបានជ្រើសរើសយកក្រុមហ៊ុន Research និង Communication Group (RCG) ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីការ ឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌សាធារណៈទៅលើការប្រយុទ្ធ ប្រឆាំងបទល្មើស នៃអំពើជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន នៅក្នុងប្រទេសកម្ពុជា ប្រទេសថៃ និងភូមា នឹងធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យអង្គការIJM យល់ដឹងកាន់តែច្បាស់ពីទិដ្ឋភាពនៃស្ថាប័ន និង រាជរដ្ឋាភិបាល បច្ចុប្បន្ន ចំពោះការប្រយុទ្ធប្រឆាំងបទល្មើសនៃអំពើជួញដូរពលកម្ម ឬជួញដូមនុស្ស នៅក្នុងប្រទេសកម្ពុជា ថៃនិងភូមា។ អង្គការ IJM កំពុងស្វែងរកឱកាស ដើម្បីបន្តការគាំទ្រដល់ប្រព័ន្ធយុត្តិធម៌សាធារណៈ ក្នុងការសម្រេច គោលដៅ របស់ស្ថាប័នខ្លួន ក៏ដូចជាសហការ និងដៃគូអង្គការ សង្គមស៊ីវិលនានា ដើម្បីការពារពលករ ឬ និយោជិត ពីអំពើជួញដូរពលកម្ម ឬអំពើជួញដូរមនុស្ស។ ការសិក្សានេះនឹងជួយដល់ការធ្វើផែនការ យុទ្ធសាស្ត្រ របស់អង្គការ IJM លើគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម។

- **ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉េន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមកិច្ចប្រជុំផ្តល់ធាតុចូល ស្តីពីសំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺអំពីករណីជួញដូរមនុស្ស នៅកម្ពុជា ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គជបជ ។ មានវត្តមានអញ្ជើញ ចូលរួមក្នុងកិច្ចប្រជុំ មានឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួង សង្គមកិច្ច ឯកឧត្តម កេង សុម៉ារិទ្ធិ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ លោកជំទាវ សួស រដ្ឋារី រដ្ឋលេខាធិការ ក្រសួងការងារ លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា ឯកឧត្តម ជ័យ រដ្ឋា អគ្គនាយករង តំណាងក្រសួងការបរទេស លោកជំទាវ ឧ.ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអគ្គស្នងការរង នៃស្នងការដ្ឋាននគរបាលជាតិ តំណាង ពីអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ អគ្គលេខាធិការរង នៃគ.ជ.ប.ជ ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស និងក្រសួងកិច្ចការនារី ប្រធានលេខាធិការដ្ឋាន មន្ត្រីជំនាញរបស់ លេខាធិការដ្ឋាន គ.ជ.ប.ជ និង មន្ត្រីពីអង្គភាពពាក់ព័ន្ធ សរុប២៩នាក់ ស្រី០៩នាក់ ។

- **ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉េន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ លោកឧត្តមសេនីយ៍ត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ លោកវរសេនីយ៍ត្រី

ធន ដារ៉ារិទ្ធ នាយរងការិយាល័យ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំតាម ប្រព័ន្ធអនឡាញ ស្តីអំពីការបន្តការងារជាមួយគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ដើម្បីពិភាក្សាលទ្ធផលសិក្ខាសាលា ស្តីពីតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ VSC និងសំណុំ ទិន្នន័យដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ២០-២២ ខែកញ្ញា ឆ្នាំ២០២២ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានការសម្របសម្រួល ដោយអង្គការ អាស៊ានអាក់ ASIAN ACT។ កិច្ចប្រជុំនេះមានការចូលរួម លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធានក្រុមជំនួយកិច្ចការទាំង៦ ប្រធានលេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.ប.ជ ទីប្រឹក្សាជាន់ខ្ពស់ នៃកម្មវិធី ASEAN ACT មន្ត្រីកម្មវិធីប្រចាំប្រទេសកម្មវិធី ASEAN-ACT កម្ពុជា និងសហការី។

**- ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និង អន្តរជាតិ និងជាសមាជិក នៃក្រុមការងារ SOMTC និងជាមន្ត្រីបង្គោល ផែនការងារប្រឆាំង ការជួញដូរមនុស្ស បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្តីពី វឌ្ឍនភាព ការងារឆ្នាំ ២០២១ និងឆ្នាំ២០២២ ព្រមទាំងទិសដៅការងារបន្ត របស់ក្រុមការងារ SOMTC កម្ពុជា ក្រោម អធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ោ ភក្តី** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ ឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា (SOMTC)។ ជាលទ្ធផលនៃកិច្ចប្រជុំ ក្រុមការងារ SOMTC ដែលមានតំណាង នៃក្រុមការងារទទួល ផែននីមួយៗ បានធ្វើបទបង្ហាញអំពី របាយការណ៍សង្ខេបស្តីពី វឌ្ឍនភាពការងារឆ្នាំ ២០២១ និង ២០២២ ព្រមទាំងទិសដៅ ការងារបន្តដែលមាន ការលើកឡើងនូវសំណើរ សំណូមពរ និងបញ្ហាប្រឈមដែលផែនទទួលបន្ទុកនីមួយៗជួបប្រទះ ព្រមទាំងផែនការដែលត្រូវត្រៀម លក្ខណៈសម្រាប់ការងារនៅឆ្នាំបន្តបន្ទាប់ទៀត។ កិច្ចប្រជុំមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកា នៃក្រុមការងារ SOMTC ព្រមទាំងមន្ត្រីពាក់ព័ន្ធផងដែរ។

**- ថ្ងៃទី២៣ ដល់ ២៤ ខែវិច្ឆិកា ឆ្នាំ២០២២** លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ត្រូវបានចាត់តាំងចូលរួម ក្នុងកិច្ចពិគ្រោះ យោបល់ពហុភាគី ស្តីពីយន្តការបញ្ជូនឆ្លងដែន (TRM) សម្រាប់មហាអនុតំបន់មេគង្គ នៅសណ្ឋាគារ អាម៉ារីវ៉ឺជេហ្គេត (Amari Water Gate) នាទីក្រុងបាងកក ។ ចូលរួមជាមួយគណៈប្រតិភូកម្ពុជា អញ្ជើញពី ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ) ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការ IOM និងសម្ព័ន្ធចាប់ដៃសរុបចំនួន ០៨រូប ។ កិច្ចពិគ្រោះយោបល់មាន គោលបំណង ជំរុញឱ្យមាន ការឯកភាពរួមគ្នាក្នុងចំណោមអ្នកបច្ចេកទេសមកពី ប្រទេសមហាអនុតំបន់មេគង្គទៅលើលក្ខណៈពិសេសនៃ យន្តការបញ្ជូនឆ្លងដែន នៅមហាអនុតំបន់មេគង្គ ក្នុងការដោះស្រាយភាពខ្វះចន្លោះនៃការបញ្ជូន កិច្ចការពារ ការធ្វើ

សមាហរណកម្ម និងការពិគ្រោះយោបល់ថ្នាក់ជាតិលើយន្តការបញ្ជូនឆ្លងដែន ព្រមទាំងរៀបចំវេទិកា ពិភាក្សាក្នុងការផ្លាស់ប្តូរចំណេះដឹង បទពិសោធន៍ល្អៗក្នុងការអនុវត្ត និងឧទាហរណ៍ថ្មីៗ នៅក្នុង កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីក្នុងចំណោមប្រទេសមហាអនុតំបន់មេគង្គ ។

- **ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉េន សិរីលក្ខិណា អគ្គលេខាធិការរង ទទួល បន្ទុកក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានអញ្ជើញចូលរួមសិក្ខាសាលា វាយតម្លៃគម្រោង "ផ្តល់សិទ្ធិអំណាចជូនស្ត្រី និងក្មេងស្រី តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ពលករចំណាកស្រុក នៅភោជនីដ្ឋានទន្លេបាសាក់២។ គោលបំណងនៃសិក្ខាសាលាគឺ ជំរុញស្ត្រី និងកុមារី អាចទប់ស្កាត់ និងលុបបំបាត់អំពើជួញដូរមនុស្សតាមរយៈ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដូចជាការដាក់ ពាក្យបណ្តឹង ឬស្វែងរកការងារ ក៏ដូចជាស្វែងរកព័ត៌មានស្តីពីការធ្វើចំណាកស្រុកសុវត្ថិភាពនៅលើ APP។

- **ថ្ងៃទី២៨ ដល់៣០ ខែវិច្ឆិកា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ិុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ អន្តរជាតិ និងជាតំណាងក្រុមការងារ SOMTC-កម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំ ឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការពលកម្ម (SLOM) និងរៀបចំការដាក់ដំណើរការគម្រោងនៃការដោះស្រាយ ការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងការនេសាទក្នុងអាស៊ាន (ALFA) ដែលប្រារព្ធឡើងនៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី។ គោលបំណងនៃកិច្ចប្រជុំគឺដើម្បី ត្រួតពិនិត្យផែនការ និងវាយតម្លៃគ្រប់ជ្រុងជ្រោយលើ ការកេងប្រវ័ញ្ចពលកម្មជាអទិភាពក្នុងវិស័យនេសាទ ក្នុងតំបន់អាស៊ាន ដែលជាពលករនេសាទ ជាពិសេសស្ត្រី និងកុមារ។ កិច្ចប្រជុំនេះធ្វើឡើងដើម្បីឆ្ពោះទៅរក កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងពហុភាគី ដោយបានធ្វើ ការអបអរសាទរនិងគាំទ្រការដាក់ដំណើរការគម្រោង ALFA នេះព្រមទាំងបានធ្វើការចែករំលែកនូវ បទពិសោធន៍ និងយន្តការរបស់អាយធា ដែលកម្ពុជាធ្វើជាប្រធាន ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិការងារ សិទ្ធស្ត្រី សិទ្ធកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរមនុស្ស ដែលធ្វើឡើងដើម្បីណែនាំ និង ផ្សព្វផ្សាយជាផ្លូវការដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមមានអាស៊ាន វិស័យឯកជន សង្គមស៊ីវិល អង្គការ ពាក់ព័ន្ធ នឹងវិស័យពលកម្ម និងដៃគូអភិវឌ្ឍន៍។

**គ-ទិសដៅបន្ត**

- បណ្តុះបណ្តាលគ្រូបង្គោលនៅមណ្ឌលទទួលពលករកំរៀង
- រៀបចំប្រព័ន្ធវីដេអូ សម្រាប់ការប្រជុំតាមប្រព័ន្ធអនឡាញ
- រៀបចំកម្មវិធីទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើរជួញដូរមនុស្ស ១២ធ្នូ

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**

**ចម្លងជូន៖**

-លេខាធិការដ្ឋានរដ្ឋបាលសរុប

-លោកជំទាវអគ្គលេខាធិការរងទទួលបន្ទុក

-លោកជំទាវអគ្គលេខាធិការ

"ដើម្បីជូនជ្រាប" ជាសេចក្តីរាយការណ៍

-ឯកសារ-កាលប្បវត្តិ